# កិច្ចការបញ្ចប់មេរៀនទី២០-មេរៀនកូនចាំ

**អំណាន:** ចូរសូត្រមេសូត្រខាងក្រោម រួចឆ្លើយនឹងសំណួរ ។

| | | |
|---|---|---|
| | មេសូត្រ ៖ បទកាកគតិ | |
| ម៉ែអើយស្ដាប់ខ្ញុំ | ពុកអើយកូនសុំ | ចង្អុលទិសប្រាប់ |
| តាមដែលកូនរៀន | ពុកប្រៀនម៉ែប្រាប់ | ថាបើនឹងរាប់ |
| | ទិសធំមានបួន ។ | |
| ទិសបូព៌ទក្សិណ | បស្ចិមរាប់មិន | មានខុសនឹងក្បួន |
| ទើបដល់ឧត្ដរ | បន្តមិនស្ទួន | កូនចេះមាំមួន |
| | ទិសតូចបួនទៀត ។ | |
| អាគ្នេយ៍និរតី | ពាយ័ព្យគ្រប់បី | កូនរាប់មិនឃ្លាត |
| ឦសានគ្រប់បួន | ដោយខ្ញុំប្រឹងឆ្លៀត | សិក្សាខ្មីឃ្មាត |
| | តាមលោកទាំងពីរ ។ | |

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើមេសូត្រខាងលើនិយាយពីអ្វី ?

☐ ក. មុខរបរចិញ្ចឹមត្រី ☐ ខ. សាលារៀន

☐ គ. ការចិញ្ចឹមសត្វ ☐ ឃ. ទិស

២. តើទិសធំមានប៉ុន្មាន ?

☐ ក. មានបួន ☐ ខ. មានប្រាំ

☐ គ. មានប្រាំមួយ ☐ ឃ. មានប្រាំបី

៣. តើទិសទាំងអស់មានប៉ុន្មាន ?

☐ ក. មានបួន ☐ ខ. មានប្រាំ

☐ គ. មានប្រាំពីរ ☐ ឃ. មានប្រាំបី

៤. តើចន្លោះទិសខាងលិច និងទិសខាងជើងជាទិសអ្វី ?

☐ ក. អាគ្នេយ៍ ☐ ខ. និរតី

☐ គ. ពាយ័ព្យ ☐ ឃ. ឦសាន

LIVEWORKSHEETS

៥. ចូរគូសភ្ជាប់ពីក្នុងតារាង ក ទៅ ខ ឱ្យបានត្រឹមត្រូវ ។

| ក | ខ |
|---|---|
| • បូព៌ | • ទិសខាងលិច |
| • ទក្សិណ | • ទិសខាងជើង |
| • បស្ចិម | • ទិសខាងកើត |
| • ឧត្តរ | • ទិសខាងត្បូង |

## ➢ សំណេរ

### ១. ចូរជ្រើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងចន្លោះឱ្យបានត្រឹមត្រូវ ។

| ទក្សិណ | ស្ងួន | ឃ្លាត | ឃ្មាត | បី | និរតី |
|---|---|---|---|---|---|

ទិសបូព៌................
ទើបដល់ឧត្តរ

អាគ្នេយ៍.............
ឦសានគ្រប់បួន

បស្ចិមរាប់មិន
បន្តមិន.............
ទិសតូចបួនទៀត ។

ពាយ័ព្យគ្រប់...........
ដោយខ្ញុំប្រឹងឆ្លៀត
តាមលោកទាំងពីរ ។

មានខុសនឹងក្បួន
កូនចេះមាំមួន

កូនរាប់មិនឃ្លាត
សិក្សាខ្មី...........

២. ចូររៀបពាក្យ ឬកន្សោមពាក្យខាងក្រោមជាល្បះឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ចេះស្តាប់ | របស់ | សិស្សល្អ | ការទូន្មាន | អ្នកគ្រូ-លោកគ្រូ ។ |

.......................................................................................................................................

| | | | | |
|---|---|---|---|---|
| យើង | ចេះគោរព | ទៅវិញទៅមក ។ | ត្រូវតែ | គ្នា |

.......................................................................................................................................

LIVEWORKSHEETS